CITY OF LONGBEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៩ ខែមេសាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបង្កើនការធ្វើតេស្តរកជំងឺកូវីដ-១៩តាមរយៈការបើកកន្លែងធ្វើតេស្តសហគមន៍ថ្មី

*ទីតាំងដែលត្រូវបានដំណើរការគឺជាផ្នែកមួយនៃការសហការរវាងរដ្ឋ ខោនធី និងក្រុមហ៊ុន OptumServe*

ទីក្រុងឡុងប៊ិចរដ្ឋកាលីហ្វ័រញ៉ា – បន្ទាប់ពីការប្រកាសរបស់លោកអភិបាលរដ្ឋ Gavin Newsom ក្នុងការបន្ថែមទីតាំងធ្វើតេស្តសហគមន៍ចំនួន ៨០ កន្លែងនៅទូទាំងរដ្ឋដែលផ្តោតលើសហគមន៍ដែលពុំមានសិទ្ធិទទួលបានទីក្រុងឡុងប៊ិចនឹងបើកទីតាំងធ្វើតេស្តនៅសាលារៀន Jordan Plus High School (171 W. Bort St.). កន្លែងធ្វើតេស្តថ្មីនឹងបើកនៅថ្ងៃទី ៣០ ខែមេសា។ ទីតាំងថ្មីនេះគឺជាកន្លែងធ្វើតេស្តមួយក្នុងចំណោម ៨០ ដែលដំណើរការដោយភាពជាដៃគូជាមួយ OptumServe ដែលជាអាជីវកម្មសេវាកម្មសុខភាពរដ្ឋាភិបាលសហព័ន្ធរបស់ Optum ដែលជាក្រុមហ៊ុនថ្មែប្រឌិតសេវាកម្មសុខភាពឈានមុខ។

លោកអភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "យើងសូមថ្លែងអំណរគុណចំពោះអភិបាលរដ្ឋ Newsom និងខោនធី Los Angeles ដែលបានបង្កើតទីតាំងធ្វើតេស្តនេះនៅឡុងប៊ិចដែលនឹងអនុញ្ញាតឱ្យប្រជាជនជាច្រើនទទួលការធ្វើតេស្ត។ ការបង្កើនសមត្ថភាពធ្វើតេស្តមានសារៈសំខាន់ណាស់ក្នុងការតាមដាន បង្ក្រាប និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។"

ការធ្វើតេស្តនឹងប្រព្រឹត្តទៅនៅសាលារៀន Jordan Plus High School ពីម៉ោង ៧ ព្រឹកដល់ម៉ោង ៧ ល្ងាចដោយមានកន្លែងចតនៅនឹងទីតាំង។ បុគ្គលិកនឹងធ្វើការអនុវត្តន៍តេស្តដោយប្រើសំឡីហើយដកយកកោសិកាពីក្នុងច្រមុះឬបំពង់ករបស់អតិថិជន។ ការធ្វើតេស្តតម្រូវឱ្យមានការណាត់ជួប។ ខាងក្រោមនេះជាព័ត៌មានសំខាន់ៗអំពីទីតាំងធ្វើតេស្តថ្មី៖

- ការធ្វើតេស្តនៅថ្ងៃទី ៣០ ខែមេសានិងថ្ងៃទី ១ ខែឧសភានៅសាលារៀន Jordan Plus នឹងមានសំរាប់តែបុគ្គលិកជួរមុខប៉ុណ្ណោះដែលរួមមានអ្នកឆ្លើយតបដំបូងចំពោះឧប្បត្តិហេតុ បុគ្គលិករដ្ឋាភិបាលសំខាន់ៗ អ្នកជំនាញព្យាបាលសុខភាព និងអ្នកលក់គ្រឿងទេស។
    - បុគ្គលអាចមិនមានរោគសញ្ញា។
    - ការណាត់ជួបត្រូវកំណត់តាមទូរស័ព្ទតែប៉ុណ្ណោះ។
    - បណ្តាញទូរស័ព្ទដើម្បីកំណត់ពេលណាត់ជួបនឹងមានសកម្មភាពនៅថ្ងៃទី ២៩ ខែមេសា។ នៅពេលនោះអ្នកធ្វើការដែលសំខាន់ៗអាចទូរស័ព្ទទៅលេខ (888) 634-1123 ដើម្បីធ្វើការណាត់ជួបសម្រាប់ថ្ងៃទី ៣០ ខែមេសានិងថ្ងៃទី ១ ខែឧសភា។
- ចាប់ផ្តើមពីថ្ងៃទី ៤ ខែឧសភាសមាជិកសហគមន៍ដែលជួបប្រទះរោគសញ្ញាក្រៅពីបុគ្គលិកសំខាន់ៗអាចចាប់ផ្តើមប្រើប្រាស់កន្លែងធ្វើតេស្តនៅសាលារៀន Jordan Plus។
    - ឧបករណ៍កំណត់ពេលណាត់ជួបនឹងមានសកម្មភាពតាមអ៊ិនធរណេតនូវថ្ងៃទី ២ ខែឧសភាសម្រាប់ការណាត់ជួបនៅសប្តាហ៍បន្ទាប់។
- ទីតាំងថ្មីនេះនឹងផ្តល់លទ្ធភាពកាន់តែច្រើនដល់ការធ្វើតេស្តនិងបន្ថែមសមត្ថភាពឱ្យមានការកើនឡើងនូវការធ្វើតេស្តនៃបុគ្គលិកនិងអ្នករស់នៅមណ្ឌលថៃទាំ។
- ទោះបីជាទីតាំងថ្មីស្ថិតនៅក្នុងទីក្រុងឡុងប៊ិចក៏ដោយមិនមានន័យថាទីតាំងនោះត្រូវបានកំណត់សម្រាប់តែអ្នករស់នៅទីក្រុងឡុងប៊ិចទេហើយទីតាំងថ្មីនេះនឹងមានភាពងាយស្រួលសម្រាប់អ្នកដែលរស់នៅទីក្រុង Signal Hill, Rancho Dominguez, Compton, Carson និង Bellflower ក្នុងចំណោមទីក្រុងដែលនៅជិតៗផ្សេងទៀត។
- ការបង្កើតទីតាំងថ្មីស្របតាមផែនការរបស់អភិបាលរដ្ឋ Newsom សម្រាប់ការពន្លឿនការធ្វើតេស្តរកជំងឺកូវីដ-១៩ដោយស្មើភាព បង្កើតក្រុមការងារតាមដានទំនាក់ទំនង បង្កើតពិធីការសម្រាប់ការញែកឱ្យនៅដាច់ដោយឯងនិងការគាំទ្រ និងការប្រើប្រាស់ប្រព័ន្ធនិងឧបករណ៍គ្រប់គ្រងទិន្នន័យ។

ដើម្បីកំណត់ទីតាំងធ្វើតេស្តថ្មីរដ្ឋាភិបាលបានពិនិត្យមើលទាំងតំបន់ជនបទនិងទីក្រុងនៅទូទាំងរដ្ឋកាលីហ្វ័រញ៉ា។ ព័ត៌ដែលបានប្រមូលត្រូវបានវាយតម្លៃដោយផ្អែកលើចំនួនប្រជាជនដែលពុំមានសិទ្ធិទទួលបានដើម្បីដោះស្រាយភាពទទួលបានខុសគ្នានិងប្រាក់ចំណូលមធ្យមភាគខុសគ្នាដើម្បីធ្វើឱ្យប្រជាជនអាចទទួលបានការធ្វើតេស្តដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចសង្គម។

OptumServe មានជំនាញយ៉ាងទូលំទូលាយក្នុងការដាក់ពង្រាយនិងតំឡើងសេវាកម្មព្យាបាលសុខភាពយ៉ាងឆាប់រហ័សហើយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយយោធាក្រោមការដឹកនាំរបស់អតីតឧត្តមសេនីយទោយោធានិងឧត្តមសេនីយ៍ឯក Patty Horoho, RN។

លោកស្រី Patty Horoho នាយកប្រតិបត្តិនៃ OptumServe មានប្រសាសន៍ថា "OptumServe មានកិត្តិយសណាស់ដែលបានជួយរដ្ឋកាលីហ្វ័រនីញ៉ាក្នុងការបង្កើនការធ្វើតេស្តនៃជំងឺកូវីដ-១៩សម្រាប់ប្រជាជន។ យើងនាំមកនូវការប្តេជ្ញាចិត្តនិងសមត្ថភាពពេញលេញរបស់យើងដើម្បីបម្រើដល់ប្រជាជនកាលីហ្វ័រញ៉ារួមទាំងបទពិសោធន៍ជាច្រើនក្នុងការធ្វើព្រឹត្តិការណ៍សុខភាពសហគមន៍ធំៗ។"

ទីតាំងថ្មីដំបូងនឹងមានសមត្ថភាពគ្រប់គ្រងការធ្វើតេស្តចំនួន ១៣២ ក្នុងមួយថ្ងៃ។ មន្ទីរសុខាភិបាលនិងសេវាប្រជាជននៃទីក្រុងឡុងប៊ិចកំពុងសហការជាមួយមហាវិទ្យាល័យទីក្រុងឡុងប៊ិចដើម្បីបើកទីតាំងថ្មីនៅស្តាត Veterans Memorial ដែលមានការធ្វើតេស្តប្រមាណ ១០០ ក្នុង ១ ថ្ងៃ។ ទីក្រុងឡុងប៊ិចគ្រោងនឹងបើកទីតាំងនេះនៅសប្តាហ៍ក្រោយ។ នៅពេលទីតាំងថ្មីទាំងពីរនេះត្រូវបានបើកដំណើរការទីក្រុងឡុងប៊ិចនឹងមានសមត្ថភាពក្នុងការធ្វើតេស្តមនុស្សជាង ៧០០ នាក់ក្នុងមួយថ្ងៃបន្ថែមពីលើបុគ្គល ២៥០ នាក់ទៀតដែលអាចធ្វើតេស្តនៅមន្ទីរពេទ្យ St. Mary។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ៖ [longbeach.gov/COVID19](longbeach.gov/COVID19) ហើយតាមដាន @LongBeachCity នៅលើហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###